Caritas CAMBODIA
CEDAC
CCC
NGO Forum on CAMBODIA
MEDiCAM
SILAKA
UPWD
USG
World Vision

វេទិកាពិភាក្សាស្តីពីអតិផរណានិងភាពក្រីក្រ, មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន, ៦ ឧសភា ២០០៨

# សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីអតិផរណានិងភាពក្រីក្រនៅកម្ពុជា៖ ការព្រួយបារម្ភនិងសេចក្តីស្នើរសុំចំណាត់ការពីសំណាក់អ្នកប្រតិបត្តិនិងអ្នករៀបចំគោលនយោបាយ

## សេចក្តីផ្តើម

ការកើនឡើងថ្លៃទំនិញប្រើប្រាស់នៅលើពិភពលោកពិសេសថ្លៃប្រេង និងម្ហូបអាហារបានក្លាយជាការព្រួយបារម្ភដ៏ធំចំពោះប្រទេសជាច្រើននាពេលថ្មីៗនេះ ពីព្រោះការកើនឡើងថ្លៃម្ហូបអាហារអាចនឹងធ្វើអោយមនុស្សរាប់លាននាក់ធ្លាក់ចូលក្នុងភាពក្រីក្រ។ ក្នុងប្រទេសមួយចំនួនភាពតានតឹង និងការអស់សង្ឃឹមរបស់ជនក្រីក្របានធ្វើអោយមានការធ្វើបាតុកម្មតវ៉ាដូចជានៅក្នុងប្រទេសហៃទី អេហ្ស៊ីប ហ្វីលីពីន ថៃ ឥណ្ឌូនេស៊ី និងអ៊ីតាលី។ ដូចគ្នានឹងប្រទេសដទៃទៀតនៅក្នុងពិភពលោក កម្ពុជាក៏ទទួលរងផលប៉ះពាល់ពីអតិផរណាខ្ពស់ដែរ ក្នុងនោះថ្លៃម្ហូបអាហារបានកើន ឡើងរហូតដល់ ២៤.២%[ii] ក្នុងចន្លោះខែមករា ឆ្នាំ២០០៧ និងខែមករា ឆ្នាំ២០០៨។ ប្រជាជនកម្ពុជាក្រីក្របំផុត២០%មានការលំបាកខ្លាំងក្នុងការដោះស្រាយជាមួយការកើនឡើងថ្លៃ ទំនិញនេះ ពីព្រោះពួកគេត្រូវចំណាយជាមធ្យមដល់ទៅ៨៣%[iii] នៃចំណាយសរុបរបស់ខ្លួនទៅលើម្ហូបអាហារ និងភេសជ្ជៈ។

## ការព្រួយបារម្ភ

### *ការកើនឡើងថ្លៃម្ហូបអាហារអាចធ្វើអោយភាពក្រីក្រនៅកម្ពុជាកាន់តែកើនឡើង*

អតិផរណាជះឥទ្ធិពលដល់មនុស្សគ្រប់ៗគ្នា ប៉ុន្តែបង្កអោយមានផលប៉ះពាល់ ខ្លាំងបំផុតទៅលើអ្នកក្រីក្រ។ អ្នកក្រីក្របំផុត ក្នុងចំណោមប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រចំណាយស្ទើរតែទាំងស្រុងនៃប្រាក់ចំណូលរបស់ខ្លួនទៅលើម្ហូបអាហារ ហើយដោយសារតែថ្លៃម្ហូបអាហារកើនឡើងខ្ពស់ អ្នកក្រីក្រទាំងនេះទំនងជាទទួលទានតិចជាងមុន ឬទទួលទានម្ហូបដែលពុំសូវមាន ជីវជាតិ។ ជាលទ្ធផលបានធ្វើអោយពួកគេកាន់តែមានភាពអត់ឃ្លាន ផលិតភាពធ្លាក់ចុះ និងរកកំរៃបានតិចជាងមុន និងអាចប្រឈមនឹងជំងឺផ្សេងៗកាន់តែខ្លាំង។ ស្ថានភាពនេះជារឿងជាក់ស្តែង ហើយដែលគ្មាននរណាម្នាក់អាចបដិសេធបានឡើយ។

ដោយសារតែប្រាក់ខែរបស់ជនក្រីក្រ និងក្រុមងាយរងគ្រោះមិនកើនឡើងច្រើនដូចអត្រាអតិផរណា ក្រុមទាំងនេះជាទូទៅធ្លាក់ចូលទៅក្នុងភាពក្រីក្រកាន់តែខ្លាំងថែមទៀត។ ករណីខ្លះមានការអះអាងថាគ្រួសារខ្លះអោយកូនឈប់រៀនដើម្បីជួយរកចំណូលផ្គត់ផ្គង់គ្រួសារ ឯគ្រួសារខ្លះទៀតឈប់អោយកូនទៅរៀនដោយសារតែពួកគេត្រូវចំណាយសម្រាប់គ្រូបង្រៀនខ្ពស់ជាងមុន[iv]។

ជារួមអតិផរណាមានផលប៉ះពាល់អវិជ្ជមានទៅ លើទ្រព្យសម្បត្តិ សុខភាព ការអប់រំ និងឱកាសចិញ្ចឹមជីវិត។

### *អតិផរណាធ្វើអោយលទ្ធភាពកាត់បន្ថយភាពក្រីក្រនៅកម្ពុជាធ្លាក់ចុះ*

ក្រៅពីការជះឥទ្ធិពលដោយផ្ទាល់ទៅលើជនក្រីក្រ ការកើនឡើងថ្លៃទំនិញជារួមនៅលើទីផ្សារធ្វើអោយកិច្ចប្រឹងប្រែងការអភិវឌ្ឍន៍នៅកម្ពុជាទាំងមូលមានការធ្លាក់ចុះ។ ជាក់ស្តែងនៅឆ្នាំ២០០៧ អង្គការការីតាសកម្ពុជាបានគ្រោងថវិកាចំនួន ១ លានដុល្លាអាមេរិកសម្រាប់ សាងសង់អគារមន្ទីរពេទ្យព្យាបាលភ្នែក

ថ្មីមួយនៅក្នុងខេត្តតាកែវ។ ប៉ុន្តែដោយសារអតិផរណាខ្ពស់ ការចំណាយលើការសាងសង់ជាក់ស្តែងនៃអគារមន្ទីរពេទ្យដដែលនេះនៅដើមឆ្នាំ២០០៨ បានកើនឡើងដល់ទៅ ១,៦ លាន ដុល្លាអាមេរិក គឺកើនឡើង ៦០%។

ករណីស្រដៀងគ្នានេះក៏អាចនឹងកើតឡើងផងដែរចំពោះថវិកាអភិវឌ្ឍន៍របស់រដ្ឋាភិបាល និងដៃគូ អភិវឌ្ឍន៍របស់ខ្លួន។ ទោះបីជាថវិការបស់រដ្ឋាភិបាលក្នុងច្បាប់ថវិកាឆ្នាំ ២០០៨ មានការកើនខ្ពស់ជាងច្បាប់ ថវិកាឆ្នាំ ២០០៧ ចំនួន ១៦%ក៏ដោយ ក៏លទ្ធផលនៃអត្រាអតិផរណាក្នុងកម្រិត ១៨.៧% ហាក់ដូចជាធ្វើឱ្យ លទ្ធភាពចំណាយជាក់ស្តែងរបស់រដ្ឋាភិបាលមានសភាពតិចជាងឆ្នាំមុន។ ការធ្លាក់ចុះនៃថវិកាពិត រួមជាមួយ នឹងឥទ្ធិពលនៃការកើនឡើងថ្លៃទំនិញនៅលើទីផ្សារទៅលើស្ថានភាពអាហារូបត្ថម្ភ និងការអប់រំរបស់គ្រួសារ នីមួយៗ ធ្វើឱ្យរាជរដ្ឋាភិបាល ស្ថិតនៅក្នុងស្ថានភាពមួយកាន់តែលំបាកជាងមុនក្នុងការសម្រេចបានគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង គោលដៅអប់រំសម្រាប់ទាំងអស់គ្នា។

### *ការកើនឡើងថ្លៃម្ហូបអាហារៈ ជាឱកាស ឬជាបញ្ហាប្រឈមសម្រាប់កម្ពុជា*

ថ្លៃម្ហូបអាហារខ្ពស់ផ្តល់នូវឱកាសសម្រាប់វិស័យកសិកម្មរបស់កម្ពុជាតាមរយៈការបង្កើនផលិតកម្ម។ ទោះបីជាកម្ពុជាប្រមូលផលស្រូវភាគច្រើនបាន១ដងក្នុងមួយឆ្នាំក្តី ក៏ប្រទេសនេះនាំចេញស្រូវប្រហែល ២លានតោនក្នុង១ឆ្នាំហើយពិតជាអាចផលិតស្រូវលើសពីតម្រូវការប្រើប្រាស់ក្នុងស្រុក[v]។ ផលិតកម្មកសិកម្ម បន្ថែមអាចជម្រុញតាមរយៈការបង្កើនចំនួនដងនៃការផលិតក្នុងមួយឆ្នាំ បង្កើនការវិនិយោគលើការគ្រប់គ្រងទឹក និងការលើកកម្ពស់សមត្ថភាពផលិតកម្មនិងស្តុក។

ឱកាសដែលថ្លៃម្ហូបអាហារខ្ពស់ផ្តល់ឱ្យ ពុំមែនមានន័យថាប្រជាជនក្រីក្រចំនួន ៩១ភាគរយដែលរស់ នៅទីជនបទនោះនឹងទទួលបានប្រាក់ចំណូលខ្ពស់ជាងមុនដោយស្វ័យប្រវត្តិឡើយ។ យោងតាមរបាយការណ៍ ចែករំលែកកំណើនរបស់ធនាគារពិភពលោកឆ្នាំ២០០៧ បានប៉ាន់ស្មានថា ប្រហែល៤៦%នៃគ្រួសារនៅជនបទ គឺជាអ្នកគ្មានដី ឬមានដីតិចជាង ០,៥ ហិចតាក្នុង១គ្រួសារ។ ទិន្នន័យនេះបង្ហាញថាជនក្រីក្រទំនងជា មិនអាចទទួលបានអត្ថប្រយោជន៍ពីការកើនឡើងថ្លៃម្ហូបអាហារទេដោយសារតែទំហំដីដែលពួកគេកាន់កាប់ មានកំណត់។ ផ្ទុយទៅវិញ គ្រួសារគ្មានដី ឬខ្វះដីនៅជនបទទាំងនេះត្រូវការទិញអង្ករបន្ថែមសំរាប់សេចក្តីត្រូវ ការប្រើប្រាស់ក្នុងគ្រួសាររបស់ខ្លួន។ បញ្ហាប្រឈមមួយទៀតសម្រាប់៦០% នៃប្រជាជនកម្ពុជាដែលធ្វើការ នៅក្នុងវិស័យកសិកម្មក្នុងការទាញយកផលប្រយោជន៍ពីឱកាសនេះគឺការកើនឡើងថ្លៃប្រេង និងកត្តាផលិតកម្មកសិកម្មដទៃទៀត។

កត្តាទាំងនេះប្រហែលជាកម្រិតផលិតភាពកសិកម្ម និងធ្វើអោយថ្លៃដើមផលិតកម្មកាន់តែខ្ពស់ ហើយជារួមអាចធ្វើឱ្យផលិតផលមិនអាចប្រកួតប្រជែងជាមួយនឹងទំនិញនាំចូលពីប្រទេសជិតខាង។ លើសពី នេះទៅទៀតកសិករកម្ពុជាភាគច្រើនមានសមត្ថភាព និងដើមទុនមានកំណត់ដើម្បីជម្រុញផលិតកម្មរបស់ខ្លួន។

### សំណើរបស់អង្គការមិនមែនរដ្ឋាភិបាល

ជាការឆ្លើយតបទៅនឹងអតិផរណាខ្ពស់ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការមួយចំនួនដើម្បីដោះស្រាយផលប៉ះពាល់នៃអតិផរណា។ អង្គការមិនមែនរដ្ឋាភិបាលសូមកោតសរសើរចំពោះរដ្ឋាភិបាលក្នុងការចាត់វិធានការទាំងនោះដើម្បីកាត់បន្ថយឥទ្ធិពលនៃអតិផរណាទៅលើជនក្រីក្រ។ លើសពីនេះទៅទៀតអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការរៀបចំ

វេទិកាពិភាក្សាថ្ងៃនេះក៏ចង់ចូលរួមចំណែកនូវយោបល់របស់ខ្លួនទៅកាន់សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ប្រទេសម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលកម្ពុជាដែលមានបំណងជួយដោះស្រាយបញ្ហារួមគ្នា។

ក្នុងប្រអប់ខាងក្រោមនេះគឺជាសេចក្តីស្នើរបស់អង្គការមិនមែនរដ្ឋាភិបាលដែលក្នុងនោះសំណើចំបងៗបីរួមមាន៖

- បង្កើនជំនួយម្ហូបអាហារ កម្មវិធីការពារសង្គមកិច្ច និងការផ្តល់ឥណទានខ្នាតតូចតាមគោលដៅ។
- ពិនិត្យឡើងវិញនូវស្តុកស្រូវឯកជន និងសាធារណៈ និងចាត់វិធានការសមស្របដើម្បីធានាថាស្តុកទាំងនេះអាចបំពេញតម្រូវការសម្រាប់ប៉ុន្មានខែបន្ទាប់នៅក្នុងឆ្នាំ២០០៨ និងដើម្បីធានាថា ស្រូវប្រាកដជាមាននៅស្តុកសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុកមុនពេលរដូវច្រូតកាត់ខាងមុខ។
- បង្កើនផលិតកម្មស្រូវ បន្លែ សាច់ និងត្រីតាមរយៈផលិតករខ្នាតតូច ដោយការជួយជម្រុញតាមរយៈ ការវិនិយោគឯកជន និងសាធារណៈនៅក្នុងវិស័យកសិកម្ម គ្រប់គ្រងទឹក និងអភិវឌ្ឍន៍ជនបទ។

***សំណើរបស់អង្គការមិនមែនរដ្ឋាភិបាលសុំឱ្យមានការដោះស្រាយចំពោះផលប៉ះពាល់របស់អតិផរណា***

**សហគមន៍**

- គួរបង្កើនផលិតកម្មម្ហូបអាហារដែលផលិតនៅតាមផ្ទះដូចជាការដាំបន្លែ ចិញ្ចឹមសត្វ និងធ្វើវារីវប្បកម្មដើម្បីជួយផ្គត់ផ្គង់តម្រូវការគ្រួសារបានគ្រប់គ្រាន់ និងឈានទៅផលិតលើសសម្រាប់លក់នៅលើទីផ្សារ។
- ស្តារ និងគ្រប់គ្រងប្រភពទឹកនិងប្រព័ន្ធធារាសាស្ត្រសម្រាប់បម្រើតម្រូវការប្រើប្រាស់របស់គ្រួសារនិងសហគមន៍។
- គ្រួសារនីមួយៗគប្បីរៀបចំដើម្បីសុវត្ថិភាពស្បៀងសម្រាប់គ្រួសាររបស់ខ្លួនឱ្យបានគ្រប់គ្រាន់។
- លើកកម្ពស់ការជ្រើសរើសពូជ បច្ចេកទេសកសិកម្ម និងសមត្ថភាពរក្សាទុក។

**អង្គការមិនមែនរដ្ឋាភិបាល**

- បង្កើនការផ្សព្វផ្សាយក្នុងការជួយឱ្យសហគមន៍យល់ដឹងពីដើមហេតុ និងឥទ្ធិពលនៃការកើនឡើងថ្លៃម្ហូបអាហារដើម្បីឱ្យពួកគេអាចត្រៀមលក្ខណៈក្នុងការទទួលបានអត្ថប្រយោជន៍ពីឱកាសដែលលេចឡើងថ្មីៗ និងការជំនះបញ្ហាប្រឈមដែលមិនបានរំពឹងទុកមុន
- គាំទ្រ និងពង្រីកគម្រោងដែលជួយធានាសន្តិសុខស្បៀងនៅកំរិតសហគមន៍ ដូចជា ការបង្កើតធនាគារស្រូវសហគមន៍ និងសហករណ៍ទីផ្សារស្រូវជាដើម។
- ដំណើរការគម្រោងដែលជួយសហគមន៍ក្នុងការផលិតម្ហូបអាហារបន្ថែមសម្រាប់ការប្រើប្រាស់របស់គ្រួសារ និងសម្រាប់ធ្វើពាណិជ្ជកម្មចំពោះការផលិតដែលលើសពីតម្រូវការប្រើប្រាស់។
- បង្កើនការគាំទ្រផ្នែកបច្ចេកទេសក្នុងការពង្រីកផលិតកម្មស្រូវតាមរយៈការប្រើប្រាស់វិធីសាស្ត្រផលិតស្រូវមួយដើម និងការជ្រើសរើសពូជស្រូវផ្សេងៗ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម។
- អនុវត្តឥណទានគោលដៅខ្នាតតូចសម្រាប់ជនក្រីក្រដូចជាមូលនិធិ Vision Fund របស់អង្គការទស្សនៈពិភពលោក គម្រោងមីក្រូហិរញ្ញវត្ថុដោយការសន្សំរបស់អង្គការសេដាក និង កម្មវិធីមូលនិធិសន្សំសហគមន៍ និង និងការអភិវឌ្ឍសហគ្រាសខ្នាតតូចរបស់អង្គការការិតាស
- ដើរតួនាទីជាភ្នាក់ងារក្នុងការផ្តល់នូវព័ត៌មានសុក្រឹត្យ និងទាន់ពេលវេលាពីតម្លៃទីផ្សារទៅឱ្យសហគមន៍

- ដើរតួនាទីជាភ្នាក់ងារក្នុងការផ្ដល់ជំនួយម្ហូបអាហារបន្តពីរដ្ឋាភិបាល ប្រទេសម្ចាស់ជំនួយ និងវិស័យឯកជនទៅកាន់ក្រុមដែលទទួលផលប៉ះពាល់ខ្លាំងបំផុត។

**វិស័យឯកជន**

- នៅក្នុងកាលៈទេសៈចាំបាច់នេះ វិស័យឯកជនគួរតែចូលរួមចំណែកមនុស្សធម៌ផងដែរទៅកាន់ប្រជាជនដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតតាមរយៈរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការមនុស្សធម៌ដទៃទៀត។
- វិនិយោគបន្ថែមក្នុងវិស័យកសិកម្មដើម្បីបង្កើតការងារ ជម្រុញផលិតកម្មក្នុងស្រុក បង្កើនចង្វាក់ផលិតកម្ម និងទីផ្សារ និងពង្រីកការនាំចេញផលិតផលសម្រេច។
- បង្កើនប្រាក់បៀវត្សរ៍ដូចេ្នះទើបបុគ្គលិក កម្មករ អាចដោះស្រាយនឹងស្ថានការកើនឡើងនៃការចំណាយការរស់នៅ។

**សហគមន៍ម្ចាស់ជំនួយ**

- បង្កើនជំនួយម្ហូបអាហារ និងបង្កើនកម្មវិធីការពារសង្គមកិច្ចដែលរួមមានៈ ជំនួយសង្គ្រោះបន្ទាន់ កម្មវិធីផ្ដល់អាហារូប-ត្ថម្ភដល់កុមារតាមសាលារៀន អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះជិតសម្រាល អាហារូបត្ថម្ភសម្រាប់ជនរងគ្រោះដោយមេរោគអេដស៍ និងរបេង គម្រោងធានារ៉ាប់រងសុខភាព និងមូលនិធិសុខាភិបាលសម្រាប់ជនក្រីក្រជាដើម។ បើតាមរបាយការណ៍ថ្មីៗនេះរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបាន បង្ហាញថា លទ្ធភាពគ្របដណ្ដប់នៃកម្មវិធីការពារសង្គមកិច្ចរបស់កម្ពុជានៅមានកម្រិតទាបបើប្រៀបធៀបទៅនឹងបណ្ដាប្រទេសផ្សេងៗដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា។
- បង្កើនបរិមាណជំនួយជាទម្រង់ជំនួយឥតសំណង និងគ្មានលក្ខខណ្ឌដើម្បីបំពេញតាមកាតព្វកិច្ចទីក្រុង Monterrey ។
- ផ្ដល់ការគាំទ្រក្នុងការលើកកម្ពស់ផលិតកម្មម្ហូបអាហារខ្នាតតូចក្នុងស្រុកដើម្បីជួយឱ្យជីវភាពរស់នៅរបស់ជនក្រីក្រមានភាពប្រសើរឡើង និងជួយឱ្យពួកគេចាកផុតពីភាពក្រីក្រ។

**រាជរដ្ឋាភិបាលកម្ពុជា**

<u>យុទ្ធសាស្ត្ររយៈពេលខ្លី</u>

- សហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីបង្កើនជំនួយម្ហូបអាហារ និងពង្រីកកម្មវិធីការពារសង្គមកិច្ចដែលបានពណ៌នាខាងលើក៏ដូចជាបង្កើនប្រាក់សោធនិវត្តរបស់រដ្ឋសម្រាប់យោធិនពិការ និងជនពិការស៊ីវិល។
- ធានាសន្តិសុខស្បៀង និងធានាថាស្តុកស្រូវ អង្ករ មានគ្រប់គ្រាន់សម្រាប់ដោះស្រាយកង្វះខាតភ្លាមៗ ឬការកើនឡើងថ្លៃទំនិញ។
- ពិនិត្យមើលឡើងវិញនូវស្តុក និងអនុវត្តវិធានការសមស្របដើម្បីធានាថាស្តុកស្រូវ អង្កររបស់ជាតិអាចបំពេញតម្រូវការសម្រាប់រយៈពេលដែលនៅសល់ក្នុងឆ្នាំ ២០០៨ និងដើម្បីធានាថាមានស្រូវអង្ករគ្រប់គ្រាន់សម្រាប់តម្រូវការប្រើប្រាស់ក្នុងស្រុក។
- លើកទឹកចិត្ត និងជួយគាំទ្រដល់ការបង្កបង្កើនផលដើមរដូវវស្សាក្នុងចន្លោះខែឧសភា និងសីហា។
- បង្កឱ្យមានទុនកាន់តែច្រើនសម្រាប់ការទិញស្រូវទុកក្នុងកំឡុងពេលប្រមូលផលបន្ទាប់នៅខែសីហា។

<u>យុទ្ធសាស្ត្ររយៈពេលវែង</u>

- បង្កឱ្យមានកំចីការប្រាក់ទាបកាន់តែច្រើនសម្រាប់ជួយជម្រុញការទិញស្រូវស្តុកទុក។
- ជួយគាំទ្រ និងជម្រុញការនាំចេញអង្ក (មិនមែនស្រូវ) ដោយផ្ទាល់។
- ជម្រុញការពង្រីកផលិតកម្មកសិកម្មដោយផ្តោតលើពូជស្រូវដែលប្រើប្រាស់កត្តាផលិតតិចដូចជា ប្រពលវប្បកម្មស្រូវមួយដើម និងជម្រុញផលិតកម្មលក្ខណៈគ្រួសារ ដូចជាការចិញ្ចឹមសត្វមាន់ ទា ការដាំដុះបន្លែ និងវារីវប្បកម្ម។
- អនុវត្តនយោបាយពន្ធទៅលើដីដែលទុកទំនេរដែលនឹងជួយលើកជម្រុញឱ្យការប្រើប្រាស់ដីទាំងនោះឱ្យមានផលិតភាព។
- ពង្រឹងការអនុវត្តច្បាប់ដីសម្បទានសេដ្ឋកិច្ច និងលប់ចោលដីសម្បទានសេដ្ឋកិច្ចណាដែលមិនមានដំណើរផលិតកម្ម។
- ផ្តល់នូវដីសម្បទានសង្គមកិច្ចទៅឱ្យសហគមន៍ដែលគ្មានដីទើបពួកគាត់អាចចូលរួមចំណែកក្នុងការបង្កបង្កើនផលដូចជាការដាំដុះស្រូវ និងការចិញ្ចឹមសត្វជាដើម។
- ស្នើរសុំឱ្យរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បង្កើនការវិនិយោគទៅលើការធ្វើប្រពលវប្បកម្មក្សេត្រសាស្ត្រ ការគ្រប់គ្រងធនធានទឹក និងអភិវឌ្ឍន៍ជនបទ ដែលវិស័យទាំងនេះកន្លងមកមានការវិនិយោគតិចតួច និងគួរតែទទួលបានជាវិស័យអាទិភាពដោយហេតុថា ៩១% នៃអ្នកក្រីក្រគឺរស់នៅតាមទីជនបទ ហើយការវិនិយោគសាធារណៈនៅក្នុងវិស័យទាំងនេះអាចជួយកសិករតូចតាច ក្នុងការបង្កើនផលិតកម្មរបស់ខ្លួន និងបង្កើនជីវភាពឱ្យបានប្រសើរឡើងនៅពេលដែលថ្លៃស្រូវអង្ករឡើងថ្លៃខ្ពស់ដូចបច្ចុប្បន្ន។
- ពិនិត្យឡើងវិញនូវវិធានការដែលបានដាក់ចេញកន្លងមកដើម្បីដឹងថាតើវិធានការទាំងនោះមាន ប្រសិទ្ធភាពក្នុងការជម្រុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាដែរឬទេ។

---

[i] International Herald Tribune April 16, 2008. UN addresses food production, poverty and rising prices.

[ii] វិទ្យាស្ថានជាតិស្ថិតិ (ខែមករា ឆ្នាំ ២០០៨)៖ សៀវភៅសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

[iii] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (ខែធ្នូ ឆ្នាំ ២០០៧)៖ សៀវភៅឃ្លាំមើលការអភិវឌ្ឍកម្ពុជា៖ អ្នកដែលរងគ្រោះបំផុតពីអតិផរណា

[iv] វេទិកាជាមួយកសិករ និងកម្មកររោងចក្រកាត់ដេរ រៀបចំដោយអង្គការការីតាសកម្ពុជា នៅខេត្តកណ្តាល ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៨។

[v] កាសែត ឃែមបូឌាដេលី ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៨៖ កម្ពុជាពុំបានបំពេញនូវសក្តានុពលភាពកសិកម្មរបស់ខ្លួន, អ្នកជំនាញការនិយាយ ទំព័រ ២៣។